# ជនបរទេសខុសច្បាប់ដែលបានបញ្ចប់ការចាក់វ៉ាក់សាំង នៅពេលរាយការណ៍ ការចាកចេញដោយស្ម័គ្រចិត្តត្រូវបានលើកលែង ការផាកពិន័យជាប្រាក់ នឹងការរឹតបន្តឹងក្នុងការត្រឡប់ចូលប្រទេសកូរ៉េវិញ

□ អ្នកដែលត្រូវបានលើកលែង

○ ចំពោះ*ជនបរទេស ខុសច្បាប់ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងនៅក្នុងប្រទេសកូរ៉េ នៅពេលរាយការណ៍ការចាកចេញដោយស្ម័គ្រចិត្ត រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

* ដែលមិនរាប់បញ្ចូល ចំពោះជនបរទេសដែលត្រូវបាន បង្ក្រាប ឬចាប់បញ្ជូនខ្លួនពីនាយកដ្ឋានប៉ូលីស ដោយសារបទល្មើសព្រហ្មទណ្ឌ អ្នកបំពានច្បាប់ ពេលធ្វើចតាឡីស័ក ។ល។

□ **ព័ត៌មានលំអិត**

○ **ការចាក់វ៉ាក់សាំង**

- អ្នកដែលបាន*បញ្ចប់ការចាក់វ៉ាក់សាំង ការចាក់ចំនួន**១ដង**(ឧ: វ៉ាក់សាំង យ៉ាន់សេន Janssen) និងការចាក់ ចំនួន**២ដង** (ឧ: វ៉ាក់សាំង ហ្វាយចាPfizer, មូដឺណាModerna, អាស្ត្រាថេនេខាAstraZeneca។ល។)

* រួមបញ្ចូលទាំងជនអន្តោប្រវេសន៍ខុសច្បាប់ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំង មុនកាលបរិច្ឆេទ**(ថ្ងៃទី12 ខែតុលា ឆ្នាំ2021)**

- ការលើកទឹកចិត្តចំពោះអ្នករាយការណ៍ ការចាកចេញដោយស្ម័គ្រចិត្ត ទោះមិនបានគ្រប់ **១៤ថ្ងៃ** ក្រោយការបញ្ចប់ការចាក់វ៉ាក់សាំង ក៏ដោយ

* ឯកសារយោង : វិញ្ញាបនប័ត្រចាក់វ៉ាក់សាំង (វិញ្ញាបនប័ត្រអេឡិចត្រូនិចទាញយកពី COOV ឬ វិញ្ញាបនប័ត្រជាក្រដាស)

○ **ការលើកទឹកចិត្ត**: លើកលែងការផាកពិន័យជាប្រាក់ និងការរឹតបន្តឹងក្នុងការត្រឡប់ចូលប្រទេសកូរ៉េវិញ ចំពោះអ្នករាយការណ៍ ការចាកចេញដោយស្ម័គ្រចិត្ត

○ ពេលវេលានៃការអនុវត្ត: ចាប់ពី **(អង្គារ៍)ថ្ងៃទី12 ខែតុលា ឆ្នាំ2021** រហូតដល់ កាលបរិច្ឆេទដែលបានបញ្ជាក់(ការអនុវត្តបណ្តោះអាសន្ន)

* កាលបរិច្ឆេទ និងត្រូវផ្លាស់ប្តូរតាមស្ថានភាព នៃជំងឺកូវីដ19 នៅពេលខាងមុខ យើងនិងចេញសេចក្តីជូនដំណឹងបន្ថែម

□ **ចំណុចសំគាល់**

○ យោងតាមប្រព័ន្ធ「រាយការណ៍ ការចាកចេញដោយស្ម័គ្រចិត្ត ដែលមានស្រាប់」

- អ្នកអាចរាយការណ៍ ការចាកចេញដោយស្ម័គ្រចិត្តជាមុនបាន តាមរយៈការរាយការណ៍ដោយផ្ទាល់ នៅក្រសួងអន្តោប្រវេសន៍ និងតាមអ៊ីនធ័រណិត
- ប្រសិនបើអ្នកបានរាយការណ៍ នៅឯព្រលានយន្តហោះ នៅថ្ងៃដែលនៅមុនពេលចាកចេញពីប្រទេស ក៏មានការលើកលែងការផាកពិន័យជាប្រាក់ និងការរឹតបន្តឹងក្នុងការត្រឡប់ចូលមកប្រទេសកូរ៉េវិញដែរ។

※ **ការសាកសួរព័ត៌មាន និងបកប្រែភាសា: មជ្ឈមណ្ឌលផ្តល់ពត៌មានសម្រាប់ជនបរទេស**(1345)

| ម៉ោងធ្វើការ | ភាសា ដែលអាចពិគ្រោះយោបល់ និងបកប្រែ |
|---|---|
| 24 ម៉ោង | អង់គ្លេស, ចិន |
| 09:00~18:00 | ភាសាជប៉ុន, វៀតណាម, ថៃ, ឥណ្ឌូនេស៊ី, រុស្ស៊ី, ម៉ុងហ្គោលី,បង់ក្លាដែស, ប៉ាគីស្ថាន, នេប៉ាល់, ខ្មែរ, មីយ៉ាន់ម៉ា, បារាំង, អាឡឺម៉ង់, អេស្ប៉ាញ, ភីលីពីន, អារ៉ាប់, ស្រីលង្កា |

<បកប្រែដោយមជ្ឈមណ្ឌល់ប្រឹក្សាតាមទូរស័ព្ទដានូរី 1577-1366>